# ព្រះរាជក្រឹត្យ

នស/រកត/០៤០៦/១៩៣

## ស្តីពី

## ការកំណត់រមណីយដ្ឋានប្រាសាទព្រះវិហារ

~~~~~~~

### យើង

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និង ការគ្រប់គ្រងធនធានធម្មជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
~~~~~~~

# ក្រោសបន្ទាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានប្រកាសកំណត់រមណីយដ្ឋានវប្បធម៌ នៃប្រាសាទព្រះវិហារជារមណីយដ្ឋានការពារស្ថិតនៅលើភ្នំព្រះវិហារ នៃជួរភ្នំដងរែកក្នុងភូមិសាឯម ( អតីតភូមិស្វាយជ្រុំ ) ឃុំកន្ទួត ស្រុកជាំក្សាន្ត ក្នុងខេត្តព្រះវិហារ ។

**មាត្រា ២.-**

ការបង្កើតរមណីយដ្ឋានការពារនេះមានគោលបំណង :

- អភិរក្សកេរដំណែលវប្បធម៌ ទាំងខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា និងលើកកំរិតតម្លៃរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត
- អភិរក្សទេសភាពវប្បធម៌ និងអភិវឌ្ឍតំបន់ទេសចរណ៍
- ការពារបរិស្ថាន និងធនធានធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្តែង ។

## ជំពូកទី ២

## ការកំណត់តំបន់

**មាត្រា ៣.-**

តម្រូវឱ្យត្រួតពិនិត្យរាល់ការអភិវឌ្ឍរមណីយដ្ឋានការពារ ដោយគោរពតាមប្លង់កំណត់តំបន់ និងការចាត់ចែងគ្រប់គ្រងតំបន់តាមចំណាត់ថ្នាក់តំបន់ត្រូវការពារ ។

**មាត្រា ៤.-**

រមណីយដ្ឋានការពារប្រាសាទព្រះវិហារ ត្រូវចាត់ជា ៤ (បួន) តំបន់ផ្សេងៗគ្នា ហើយត្រូវទទួលកំរិតការពារខុសៗគ្នា :

ក - តំបន់ទី ១ : ជាតំបន់រមណីយដ្ឋានមានប្រាសាទ ហៅថា តំបន់ស្នូល មានផ្ទៃក្រឡាសរុប ១៥៤.៧ ហិកតា កំណត់យកតួភ្នំទាំងមូល គិតចាប់ពីកំពូលភ្នំនៃប្រាសាទព្រះវិហារ ដែលមានខ្សែរយៈកំពស់ ៦២៥ ម៉ែត្រ ចុះក្រោមរហូតដល់ខ្សែរយៈកំពស់៥០០ម៉ែត្រ កំណត់ដោយចំណុចដែលមានខ្សែរយៈទទឹង និងខ្សែរយៈបណ្តោយ ដូចតទៅ :

| ចំណុច | រយៈទទឹង | រយៈបណ្តោយ |
|---|---|---|
| 1 | 14° 23' 59" | 104° 41' 30" |
| 2 | 14 23 41 | 104 41 20 |
| 3 | 14 23 28 | 104 41 18 |
| 4 | 14 23 13 | 104 41 07 |
| 5 | 14 23 18 | 104 40 52 |
| 6 | 14 23 27 | 104 40 41 |
| 7 | 14 23 44 | 104 40 33 |
| 8 | 14 23 49 | 104 40 34 |
| 9 | 14 23 50 | 104 40 41 |

/៤/

និងខ្សែបន្ទាត់ព្រំដែនកម្ពុជា ថៃ រាប់បញ្ចូលទាំងជណ្តើរប្រវត្តិសាស្ត្រ ដែលស្ថិតនៅចំហៀងខាងកើតភ្នំ ហើយដែលមានខ្សែរយៈទទឹង និងខ្សែរយៈបណ្តោយ ដូចតទៅ :

| ចំណុច | រយៈទទឹង | | | រយៈបណ្តោយ | | |
|---|---|---|---|---|---|---|
| T | 14° | 23’ | 16’’ | 104° | 42’ | 12’’ |
| 2 | 14 | 23 | 41 | 104 | 41 | 20 |
| 10 | 14 | 23 | 41 | 104 | 41 | 05 |

ដោយត្រូវរក្សាការពារចំណីជណ្តើរ ៥០ ម៉ែត្រ សងខាងជណ្តើរផងដែរ ។

តំបន់នេះ ជាតំបន់មានប្រាសាទព្រះវិហារសំខាន់ជាងគេក្នុងរមណីយដ្ឋានការពារ ហើយត្រូវទទួលកិច្ចការពារកំរិតខ្ពស់បំផុត ។

ខ - តំបន់ទី ២ : ជាតំបន់អភិរក្សឧទ្យានបុរាណវត្ថុ និងទេសភាពវប្បធម៌ បរិស្ថានធម្មជាតិ ហៅថាតំបន់ទ្រនាប់ដែលមានផ្ទៃក្រឡាសរុប ២៦៤២.៥ ហិកតា ។

តំបន់នេះ ត្រូវបានកំណត់យកផ្ទៃដីចន្លោះខ្សែបន្ទាត់ បរិវេណនៃតំបន់ស្នូល និងខ្សែបន្ទាត់ព្រំដែនកម្ពុជា ថៃ ហើយនិងខ្សែបន្ទាត់អ័ក្សផ្លូវដែលចាប់ផ្តើមពីមាត់ច្រកតំបន់ព្រំដែនតាថាវ តាមបណ្តោយផ្លូវកាត់តាមបណ្តាចំណុច T, B, C (ភូមិ គ១)និង D បត់ឡើងទៅលើភ្នំប្រាសាទព្រះវិហារ រហូតដល់ខ្សែកំពស់ ៥០០ ម៉ែត្រ ហើយដែលមានខ្សែរយៈទទឹង និង ខ្សែរយៈបណ្តោយ ដូចខាងក្រោម :

| ចំណុច | រយៈទទឹង | | | រយៈបណ្តោយ | | |
|---|---|---|---|---|---|---|
| B | 14° | 22’ | 19” | 104° | 42’ | 48” |
| C | 14 | 22 | 34 | 104 | 40 | 02 |
| D | 14 | 23 | 22 | 104 | 40 | 08 |
| T | 14 | 23 | 16 | 104 | 42 | 12 |

ក៏ត្រូវបានរាប់បញ្ចូលក្នុងតំបន់ទី ២ ផងដែរ នូវតំបន់ដែលមានផ្ទៃដីកំណត់ដោយមុំ ៦០ អង្សារ ដែលមានចំណុចផ្តើម O ស្ថិតនៅខ្សែរយៈកំពស់ ៦២៥ ម៉ែត្រលើកំពូលភ្នំប្រាសាទព្រះវិហារ បែរមុខត្រង់ឆ្ពោះទៅទិសខាងត្បូង ហើយមានបន្ទាត់ខ្សែរយៈបណ្តោយ ជាបន្ទាត់បែងចែកមុំពាក់កណ្តាលស្មើគ្នា ។ ខ្សែបន្ទាត់មុំ O ទាំងពីរកាត់អ័ក្សផ្លូវ B, C បានជាចំណុច F, G ហើយកាត់រង្វង់មូលកោងដែលមានកាំចម្ងាយប្រវែង ៥ គីឡូម៉ែត្រ បានជាចំណុច L, K ដែលមានខ្សែរយៈទទឹង និង ខ្សែរយៈបណ្តោយ ដូចខាងក្រោម :

| ចំណុច | រយៈទទឹង | | | រយៈបណ្តោយ | | |
|---|---|---|---|---|---|---|
| O | 14° | 23’ | 18” | 104° | 41’ | 02” |
| F | 14 | 22 | 37 | 104 | 40 | 39 |
| G | 14 | 22 | 29 | 104 | 41 | 32 |
| K | 14 | 20 | 56 | 104 | 42 | 29 |
| L | 14 | 20 | 55 | 104 | 39 | 40 |

តំបន់ទី ២ ដែលជាឧទ្យានបុរាណវត្ថុត្រូវការពារ ដូចមានចែងក្នុងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជាអចលនទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ។ រាល់ការលក់ដូរ ដោះដូរ ឬ សម្បទានអ្វីមួយទៅលើដីធ្លី ដែលស្ថិតក្នុងតំបន់ទី ២ ត្រូវចាត់ទុកជាមោឃៈ ។

តំបន់នេះសម្បូរដោយសំណល់បុរាណវត្ថុ ដែលត្រូវការពារទប់ស្កាត់ ការប្រើប្រាស់ដីធ្លី និងការអភិវឌ្ឍមិនសមស្រប ។

គ -តំបន់ទី ៣ : ជាតំបន់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច និង សង្គមកិច្ច ហៅថាតំបន់របាប មានផ្ទៃក្រឡា សរុប ២.៨២៨.៩ ហិកតា ដោយរក្សាជីវភាព មុខរបរ អាជីវកម្មតាមទំនៀមទម្លាប់ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ស្រាប់ ។

តំបន់ទី ៣ នេះ ត្រូវបានចែកជា ២ (ពីរ ) តំបន់ដាច់គ្នា គឺ តំបន់ទី ៣ក ដែលមានផ្ទៃក្រឡា ៦៧៩.១ ហិកតា និងតំបន់ទី ៣ខ ដែលមានផ្ទៃក្រឡា ១១៤៩.៨ ហិកតា ។

ដីធ្លីទាំងអស់ដែលស្ថិតនៅក្នុងតំបន់ទី ៣ ក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារ គឺជាដីទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។ រាល់បណ្តាគំរោងអភិវឌ្ឍន៍ ក្នុងតំបន់ ៣ក និង ៣ខ ត្រូវអនុវត្តតាមប្លង់គោល ប្លង់ប្រើប្រាស់ដីធ្លី និងបទប្បញ្ញត្តិពិសេសទាំងឡាយដែលពាក់ព័ន្ធ ដល់ការរៀបចំអភិវឌ្ឍន៍ នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

តំបន់នេះជាគោលដៅថែរក្សាបេតិកភ័ណ្ឌវប្បធម៌ និងធម្មជាតិតាមរយៈការចាត់ចែងវិធានការ ដើម្បីជំរុញការអភិវឌ្ឍឱ្យមានចីរភាព និងមានការវាយតម្លៃហេតុប៉ះពាល់លើបរិស្ថាន ។

ឃ-តំបន់ទី ៤ : ជាតំបន់ដែលតម្រូវឱ្យមានការអភិរក្សធនធានធម្មជាតិ អនុវត្តន៍តាមព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និង តាមព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ រួមទាំងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០២ ស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃ "ព្រះវិហារ" ។

ប្លង់កំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ មានក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣
## ការគ្រប់គ្រង ថែទាំ និង ការពារ

**មាត្រា ៥.-**

ការអភិរក្សតំបន់នីមួយៗ ត្រូវបានគ្រប់គ្រង ថែទាំ និងការពារ ស្របតាមទិសដៅចំណាត់ថ្នាក់តំបន់ ដូចមានចែងក្នុងមាត្រា៤ នៃព្រះរាជក្រឹត្យនេះ និង កំរិតនៃសារៈសំខាន់ដោយឡែកៗ ខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ធម្មជាតិ គោរពសិទ្ធិជាម្ចាស់របស់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ទាំងមូល ខាងជីវភាពរស់នៅ និងលើកស្ទួយរមណីយដ្ឋានការពារឱ្យមានតម្លៃកាន់តែប្រសើរឡើង ។

**មាត្រា ៦.-**

ត្រូវអនុវត្តនូវនយោបាយរបស់ក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីធានាការគ្រប់គ្រង ថែទាំ និងការពារ ដោយកំណត់ភាពម្ចាស់ការទទួលខុសត្រូវរបស់បណ្តាស្ថាប័នមានសមត្ថកិច្ចដែលមានក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ ទទួលអនុវត្តផ្ទាល់ ។

យោងលើមាត្រា ៥ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ នៅតំបន់ប្រាសាទព្រះវិហារ ការការពារថែរក្សា និងលើកតម្លៃ

បេតិកភ័ណ្ឌវប្បធម៌ជាតិ ត្រូវប្រគល់ឱ្យអាជ្ញាធរមួយ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់ប្រាសាទព្រះវិហារ ដែលនឹងត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ ។

អាជ្ញាធរនេះ ត្រូវទទួលភារកិច្ចផ្តាច់មុខ ជាអ្នកចាត់ចែងពិធីគ្រប់ជំពូកទាំងអស់ ក្នុងបរិវេណរមណីយដ្ឋានប្រាសាទព្រះវិហារ ។ ដើម្បីបំពេញបេសកកម្មទាំងនេះបាន អាជ្ញាធរមានសិទ្ធិផ្តាច់មុខ ក្នុងការចេញលិខិតអនុញ្ញាតសាងសង់ ចំពោះការស្ថាបនាទាំងឡាយក្រៅបរិវេណការពាររមណីយដ្ឋានប្រាសាទព្រះវិហារ ។

ការអនុញ្ញាតសាងសង់ ដែលចេញដោយអាជ្ញាធរផ្សេងពីអាជ្ញាធរខាងលើ ទាក់ទងនឹងសំណង់នៅរមណីយដ្ឋាន ត្រូវចាត់ទុកជាមោឃៈ ។

បែបបទ និងនីតិវិធី នៃការគ្រប់គ្រង ថែទាំ និងការពាររមណីយដ្ឋានប្រាសាទព្រះវិហារ ក្នុងបណ្តាមាត្រាខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧.-**

បរិវេណ និងរាល់សកម្មភាពនៅក្នុងតំបន់នីមួយៗ នៃរមណីយដ្ឋានការពារប្រាសាទព្រះវិហារ អាចត្រូវបានពិនិត្យឡើងវិញហើយកែប្រែបានដោយផ្អែកលើរាល់លទ្ធផលនៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាពជាក់ស្តែង ដើម្បីធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តរភាព ដូចមានចែងក្នុងមាត្រា៤ នៃព្រះរាជក្រឹត្យនេះ។

ការកែប្រែតំបន់ និង រាល់សកម្មភាពពាក់ព័ន្ធនឹងរមណីយដ្ឋានប្រាសាទព្រះវិហារ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ តាមសំណើរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១១៥ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

នស.រកត.០៤០៦.១៩២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ហត្ថលេខា**

**សុខ អាន**

លេខ: ១៧៤៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមេសាឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង គាន់

៥/៦




# ផែនទីកំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

ឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យលេខ នស/រកត/០៤០៦/១៩៣

ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ២០០៦

ស្ដីពីការកំណត់តំបន់រមណីយដ្ឋានប្រាសាទព្រះវិហារ

មាត្រដ្ឋាន 1:55000

**សញ្ញាសំគាល់**

- ព្រំប្រទល់ប្រទេស
- ផ្លូវ
- ខ្សែរយៈកំពស់៥០០ម.
- ខ្សែព្រំប្រទល់តំបន់ទ្រនាប់
- តំបន់ស្នូល ១៥៤.៧ហត
- តំបន់ទ្រនាប់ ២៦៤២.៥ហត
- តំបន់ទេសភាព : 3a -១៦៧៥.១ហត 3b -១១៤៥.៨ហត

| ចំណុច | រយៈទទឹង | រយៈបណ្ដោយ |
|---|---|---|
| -តំបន់ស្នូល | | |
| 1 | 14°23′59″ | 104°41′30″ |
| 2 | 14 23 41 | 104 41 20 |
| 3 | 14 23 28 | 104 41 18 |
| 4 | 14 23 13 | 104 41 07 |
| 5 | 14 23 18 | 104 40 52 |
| 6 | 14 23 27 | 104 40 41 |
| 7 | 14 23 44 | 104 40 33 |
| 8 | 14 23 49 | 104 40 34 |
| 9 | 14 23 50 | 104 40 41 |
| 10 | 14 23 41 | 104 41 05 |
| -តំបន់ទ្រនាប់ | | |
| B | 14 22 19 | 104 42 48 |
| C | 14 22 34 | 104 40 02 |
| D | 14 23 22 | 104 40 08 |
| T | 14 23 16 | 104 42 12 |
| F | 14 22 37 | 104 40 39 |
| G | 14 22 29 | 104 41 32 |
| H | 14 22 07 | 104 43 15 |
| I | 14 21 23 | 104 43 03 |
| J | 14 21 12 | 104 42 51 |
| K | 14 20 56 | 104 42 29 |
| L | 14 20 55 | 104 39 40 |
| M | 14 21 07 | 104 39 09 |
| N | 14 21 49 | 104 38 29 |
| -ចំណុចកំពូលម៉ុំឪឌុប | | |
| O | 14 23 18 | 104 41 02 |

ប្រភពផែនទី :

.ផែនទី ដងរែក របស់គណៈកម្មការកំណត់ព្រំដែនកម្ពុជា-សៀម ខ្នាត ១: ២០០០០០

.ផែនទី ខ្នាត ១:៥០០០០ សេរីL7016 សន្លឹក5937IV

.ទិន្នន័យវាស់វែងដោយ GPS ឆ្នាំ២០០២. ២០០៥

.រូបភាពផ្កាយរណប SPOT ឆ្នាំ១៩៩៩

រៀបចំដោយនាយកដ្ឋានភូមិសាស្ត្រ.១២.២០០២. កែសំរួល.១២.២០០៥.